ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រុងប្រយ័ត្នមុនពេលសម្រេចចិត្តទៅធ្វើការនៅបរទេស

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់សាធារណជន ជាពិសេសប្រជាពលរដ្ឋដែលមានបំណងស្វែងរកការងារធ្វើនៅបរទេសឱ្យបានជ្រាបថា ក្រសួងបានកត់សម្គាល់ឃើញមានជនឆ្លៀតឱកាសបានប្រើប្រាស់បណ្តាញសង្គម (ហ្វេសប៊ុក តិកតុក តេឡេក្រាម...) ផ្សព្វផ្សាយព័ត៌មានពីការសម្របសម្រួលផ្តល់សេវា និងរត់ការជួយប្រជាពលរដ្ឋដើម្បីទៅធ្វើការនៅប្រទេសមួយចំនួនដែលមិនមានកិច្ចសហប្រតិបត្តិការលើការទទួលយកពលករពីប្រទេសកម្ពុជា រួមទាំងការសម្របសម្រួលដល់ប្រជាពលរដ្ឋដើម្បីចេញទៅរស់នៅបរទេសដោយពុំមានការបញ្ជាក់ត្រឹមត្រូវច្បាស់លាស់ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

ឆ្លៀតក្នុងឱកាសនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមក្រើនរំលឹកដល់សាធារណជនដែលមានបំណងទៅធ្វើការនៅបរទេស ត្រូវស្វែងយល់ពីនីតិវិធីឱ្យបានច្បាស់លាស់ និងជ្រើសរើសទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ ដែលទទួលបានការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីជៀសវាងការធ្វើទេសន្តរប្រវេសន៍ការងារដោយប្រថុយប្រថាន ដែលអាចនាំឱ្យធ្លាក់ខ្លួនជាជនរងគ្រោះ នៃអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម។ ការបញ្ជូន ឬជួយសម្របសម្រួលឱ្យបុគ្គលណាមួយចេញទៅធ្វើការនៅបរទេសដោយពុំមានការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាអំពើជួញដូរមនុស្ស ដែលប្រឈមនឹងការផ្តន្ទាទោសជាប់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ដូចមានចែងក្នុងមាត្រា៨ ដល់មាត្រា១៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

ទន្ទឹមនឹងនេះ ក្រសួងសូមអំពាវនាវដល់សាធារណជនមានការប្រុងប្រយ័ត្នខ្ពស់ ជៀសវាងការខាតបង់ពេលវេលា និងប្រាក់កាសដោយជនខិលខូចមួយចំនួន ដែលបានផ្សព្វផ្សាយតាមបណ្តាញសង្គមអំពីការធានារត់ការសម្របសម្រួលជូនបងប្អូន ដើម្បីបានចេញទៅរស់នៅ និងធ្វើការនៅបរទេស។ សូមសាធារណជនសហការផ្តល់ព័ត៌មានដល់ស្ថាប័នពាក់ព័ន្ធ ក្នុងករណីដែលមានបុគ្គលណាមួយផ្តល់សេវានេះដោយគ្មានលិខិតអនុញ្ញាតត្រឹមត្រូវ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

សម្រាប់ព័ត៌មានបន្ថែមអំពីការងារនៅបរទេស សូមទំនាក់ទំនងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈប្រព័ន្ធ Hotline លេខ ១២៨៦ ឬ ១២៩៧ ឬក្រុមតេលេក្រាម "សម្រាប់ ពលករទេសន្តរប្រវេសន៍" ( https://t.me/KhmerMigrantWorker ) ឬ "ប្រអប់បណ្តឹងអនាមិក" ( https://feedback.mlvt.gov.kh ) ដែលអាចភ្ជាប់តាមរយៈការស្កេន QR Code ខាងក្រោម ឬទំនាក់ទំនងមកមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ឬពិនិត្យមើលបញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជនដែលមាននៅក្នុងគេហទំព័ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ( https://www.mlvt.gov.kh ) ឬប្រព័ន្ធតាមដានពលករទេសន្តរប្រវេសន៍ ( https://www.tracking.ocwc.co )។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃ សុក្រ ១១កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០២៤

សូមផ្តល់ព័ត៌មានតាមរយៈ៖

១. ប្រព័ន្ធ Telegram "សម្រាប់ ពលករទេសន្តរប្រវេសន៍"

២. ប្រអប់បណ្តឹងអនាមិក